ឆ្នាំទី ២ លេខ ១០ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០២ រាជកិច្ច ទំព័រ ៦២៤

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

*****

**ក្រសួងអប់រំ យុវជន និង កីឡា**

លេខ......៤៤៧......អយក.ប្រក

# ប្រ កា ស

*******

ស្តីពីការបើកវិទ្យាល័យ « កំពង់ឈើទាល ស្រុកប្រាសាទសំបូរ »

ស្ថិតក្នុងឃុំសំបូរ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា។
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ ។
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា ។
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២។
- យោងលិខិតស្នើសុំរបស់មន្ទីរអប់រំ យុវជន និងកីឡា លេខ ១៥៨៩ អយក.កធ.រប ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០១ ដោយមានយោបល់ឯកភាពពីអភិបាលខេត្តកំពង់ធំ ។
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ ។

**ស ម្រេ ច**

**ប្រការ ១ :** អនុញ្ញាតអោយបើកវិទ្យាល័យដែលមានឈ្មោះថា : វិទ្យាល័យ « កំពង់ឈើទាល ស្រុកប្រាសាទសំបូរ » ស្ថិតនៅក្នុងឃុំសំបូរ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ ២ :** វិទ្យាល័យនេះផ្តល់ពុទ្ធិទូទៅនៅកំរិតមធ្យមសិក្សាបឋមភូមិ និងពុទ្ធិទូទៅផង វិជ្ជាជីវៈផងនៅកំរិតមធ្យមសិក្សាទុតិយភូមិ ។

**ប្រការ ៣ :** វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខនៃវិទ្យាល័យ ។

**ប្រការ ៤ :** នាយក_នាយករងនៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៥ :** អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកអប់រំ ប្រធាននាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំយុវជននិងកីឡា ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ និងនាយកវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ១៤ ខែ មិនា ឆ្នាំ ២០០២

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

រដ្ឋលេខាធិការ

អ៊ឹម_សិទ្ធី

<u>កន្លែងទទួល</u> :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន "
- សាលាខេត្តកំពង់ធំ " ដើម្បីជាពត៌មាន "
- ដូចប្រការ ៥
- កាលប្បវត្តិ_ឯកសារ នា.មចទ